គណៈឆ្មបកម្ពុជា
Cambodian Midwives Council

## ទិវាឆ្មបជាតិ ២ ឧសភា ឆ្នាំ២០២៤

# អនុក្រឹត្យ
# ស្តីពី
# ក្រមសីលធម៌ឆ្មប

## ក្រុមប្រឹក្សាគណៈឆ្មបជាតិ


**បង្ហាញដោយ កញ្ញា ខួន សុភាព**

មន្ត្រីបម្រើការនៅនាយកដ្ឋានមន្ទីរពេទ្យ និង ជាប្រធានគណៈឆ្មបកម្ពុជា


ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៤ នៅសណ្ឋាគារកាំបូឌីយ៉ាណា

# សេចក្ដីសម្រេច
# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១._**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់សីលធម៌ សេចក្តីថ្លៃថ្នូរ ភាពសុចរិត ប្រសិទ្ធភាព វិន័យការងារ ក្នុងការប្រកបវិជ្ជាជីវៈរបស់ឆ្មប និងជាពិសេសទទួលបានទំនុកចិត្តពីសាធារណជន។

**មាត្រា ២._**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីក្រមសីលធម៌វិជ្ជាជីវៈឆ្មបក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣._**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះឆ្មបទាំងអស់ ដែលទទួលបានការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈឆ្មបពីក្រសួងសុខាភិបាល។

**មាត្រា ៤.**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចខាងក្រោម៖

ឆ្មបសំដៅដល់នីតិជនដែលមានសញ្ញាបត្រឆ្មបចេញដោយក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬសញ្ញាបត្រឆ្មបចេញដោយគ្រឹះស្ថានសិក្សាដែលបានទទួលស្គាល់គុណភាពអប់រំដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

វិជ្ជាជីវៈឆ្មបសំដៅដល់ការផ្តល់សេវាថែទាំ ការគាំទ្រ ការផ្តល់ដំបូន្មានចាំបាច់ក្នុងអំឡុងពេលមានគភ៌ ពេលសម្រាល និងក្រោយពេលសម្រាល និងការផ្តល់សេវាសម្រាលដោយទទួលខុសត្រូវរួមទាំងផែនការគ្រួសារនិងពន្យារកំណើត ការរំលូតប្រកបដោយសុវត្ថិភាព ព្រមទាំងការថែទាំទារកទើបនឹងកើតផង។

គ្រឹះស្ថានឆ្មបសំដៅដល់កន្លែងដែលឆ្មបបម្រើការងារឆ្មប ដូចជា មន្ទីរពេទ្យ មន្ទីរសម្ភព មណ្ឌលសុខភាព គ្លីនិក និងបន្ទប់ថែទាំឯកជន ដែលមានការទទួលស្គាល់ឬការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

# ជំពូកទី២
# ករណីយកិច្ចនិងការទទួលខុសត្រូវទូទៅរបស់ឆ្មប

**មាត្រា ៥.-**

ដើម្បីសម្រេចករណីយកិច្ចនិងការទទួលខុសត្រូវទូទៅរបស់ខ្លួន ឆ្មប៖

១- ត្រូវបំពេញការងារដោយមានការទទួលខុសត្រូវនិងមានគណនេយ្យភាព ហើយធ្វើការជាដៃគូជាមួយស្ត្រី ដៃគូគ្រួសារ និងអាណាព្យាបាលរបស់គាត់។

២- ត្រូវបំពេញការងារដោយគោរពតាមច្បាប់ បទប្បញ្ញត្តិជាធរមាន គោលការណ៍ណែនាំជាតិ និងពិធីសារជាតិដែលទាក់ទងនឹងវិជ្ជាជីវៈឆ្មប។

៣- ត្រូវប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវឥស្សរភាពវិជ្ជាជីវៈ នៅគ្រប់កាលៈទេសៈទាំងអស់។

៤- ត្រូវចូលរួមអនុវត្តគោលនយោបាយយុទ្ធសាស្ត្រជាតិឱ្យមានប្រសិទ្ធភាពនិងសហការគ្នាក្នុងការប្រកបវិជ្ជាជីវៈឆ្មប ដើម្បីរួមចំណែកក្នុងការលើកកម្ពស់សុខភាពមាតានិងទារក។

៥- ត្រូវផ្តល់សេវាប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព ដោយមានគុណធម៌ អាកប្បកិរិយាល្អ សម្តីសុភាពរាបសា ត្រឹមត្រូវ និងយកចិត្តទុកដាក់។

៦- ត្រូវអភិវឌ្ឍសមត្ថភាពខ្លួនជាប្រចាំ តាមរយៈការចូលរួមបណ្តុះបណ្តាលបន្ត ការស្រាវជ្រាវ ការទទួលព័ត៌មានបន្ថែមថ្មីៗ។

៧- ត្រូវអភិវឌ្ឍវិជ្ជាជីវៈឆ្មបតាមរយៈការចូលរួមរៀបចំនិងកែលម្អពិធីសារជាតិ គោលការណ៍ណែនាំជាតិ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ។

៨- ត្រូវគោរពជីវិត រាងកាយ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ត្រី នៅពេលផ្តល់សេវា។

៩- ត្រូវគោរពការសម្ងាត់វិជ្ជាជីវៈនិងបទប្បញ្ញត្តិដែលពាក់ព័ន្ធនានា ដើម្បីរក្សាភាពជាឯកជន កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ត្រី។

១០- ត្រូវគោរពសិទ្ធិរបស់ស្ត្រីក្នុងការជ្រើសរើសឆ្មបនិងត្រូវជួយសម្របសម្រួលដល់ស្ត្រីក្នុងការជ្រើសរើសឆ្មបដោយឆន្ទៈរបស់សាមីខ្លួន។

១១- ត្រូវផ្តល់សេវាចំពោះស្ត្រី ដោយគ្មានការរើសអើងចំពោះពូជសាសន៍ ពណ៌សម្បុរ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ឋានៈសង្គម ធនធាន ឬស្ថានភាពដទៃទៀត។

១២- ត្រូវចូលរួមផ្តល់មតិដើម្បីការពារសិទ្ធិរបស់ស្ត្រី គ្រួសារ និងសហគមន៍ដែលមានទំនាក់ទំនងជាមួយនឹងការថែទាំសុខភាពមាតានិងទារក រាប់បញ្ចូលទាំងសិទ្ធិក្នុងការមានផ្ទៃពោះ។

**មាត្រា ៦._**

ឆ្មបផ្តល់ឱសថតាមវេជ្ជបញ្ជានិងតាមគោលការណ៍ណែនាំថ្នាក់ជាតិរបស់ក្រសួងសុខាភិបាល។

**មាត្រា ៧._**

ឆ្មបត្រូវស្ថិតនៅជាមួយស្ត្រីមានគភ៌ដែលហៀបនឹងសម្រាល កំពុងសម្រាល ទើបសម្រាលថ្មីៗ និងទារកទើបនឹងកើត។ ក្នុងករណីមាតានិង/ឬទារកស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ឆ្មបត្រូវផ្តល់សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភពនិងថែទាំទារក ឬត្រូវធ្វើការសង្គ្រោះបឋមនិងបញ្ជូនទៅសេវាឆ្មបឬសេវាសមស្របផ្សេងទៀតតាមការចាំបាច់។

**មាត្រា ៨._**

ឆ្មបដែលត្រូវបានអាជ្ញាធរមានសមត្ថកិច្ចសុំឱ្យពិនិត្យឬប្រឹក្សាយោបល់ទាក់ទងទៅនឹងវិជ្ជាជីវៈឆ្មបតាមរយៈអង្គភាពនិងស្ថាប័ន ដល់ស្ត្រីជាជនសង្ស័យនិងជនជាប់ឃុំ ត្រូវជូនដំណឹងត្រឡប់ដល់អាជ្ញាធរមានសមត្ថកិច្ចពីស្ថានភាពសុខភាពរបស់ស្ត្រី។

**មាត្រា ៩.-**

ដើម្បីអនុវត្តករណីយកិច្ចនិងការទទួលខុសត្រូវទូទៅរបស់ខ្លួនឱ្យបានល្អ ឆ្មប៖

១- មិនត្រូវធ្វើការងារណាដែលនាំឱ្យប៉ះពាល់ អាប់ឱនកិត្តិយស និងសេចក្តីថ្លៃថ្នូរដល់វិជ្ជាជីវៈឆ្មបឡើយ។

២- មិនត្រូវប្រើឥទ្ធិពលរបស់ខ្លួនដើម្បីទទួលបាននូវកិច្ចសន្យា បុព្វសិទ្ធិ សិទ្ធិឬផលប្រយោជន៍ពីអ្នកជំងឺ។

៣- មិនត្រូវប្រព្រឹត្តអំពើដែលមានទំនាស់ផលប្រយោជន៍ជាមួយនឹងគ្រឹះស្ថានឆ្មបក្នុងការបញ្ជូនស្ត្រីដើម្បីប្រាក់កម្រៃជើងសាឬថ្លៃសេវាឡើយ។

៤- មិនត្រូវបំពេញការងារឆ្មបនៅទីសាធារណៈ លើកលែងតែក្នុងករណីសង្គ្រោះបន្ទាន់។

៥- មិនត្រូវចេញវិញ្ញាបនបត្រនិងលិខិតបញ្ជាក់ផ្សេងៗដែលទាក់ទងនឹងវិជ្ជាជីវៈឆ្មប។

៦- មិនត្រូវទារថ្លៃសេវាហួសកម្រិតឬផ្តល់ព័ត៌មានក្លែងក្លាយទាក់ទងនឹងកម្រៃសេវារបស់ខ្លួន។

៧- មិនត្រូវប្រើរហស្សនាមក្នុងការប្រកបវិជ្ជាជីវៈឆ្មប។

៨- មិនត្រូវផ្សព្វផ្សាយជាលក្ខណៈពាណិជ្ជកម្មអំពីសេវារបស់ខ្លួនដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល។

៩- មិនត្រូវបង្ហាញអត្តសញ្ញាណរបស់ស្ត្រីតាមរយៈការផ្សព្វផ្សាយជាសាធារណៈឬក្នុងគោលបំណងវេជ្ជសាស្ត្រឡើយ លើកលែងតែមានការយល់ព្រមពីស្ត្រីដែលជាសាមីខ្លួន។

១០-មិនត្រូវបានអនុញ្ញាតឱ្យចេញវេជ្ជបញ្ជាទូទៅឬលក់ឱសថឡើយ។

១១-មិនត្រូវផ្តល់សេវាឬប្រឹក្សាយោបល់ក្រៅពីវិជ្ជាជីវៈឆ្មបដែលមិនស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួនឡើយ លើកលែងតែក្នុងករណីចាំបាច់ដែលត្រូវសង្គ្រោះបន្ទាន់។

**មាត្រា ១០.-**

ឆ្មបដែលមានតួនាទីក្នុងអាណត្តិជាប់ឆ្នោតឬតំណែងផ្លូវការណាមួយ មិនត្រូវប្រើតួនាទីនោះដើម្បីទាក់ទាញអតិថិជនឡើយ។

# ជំពូកទី៣
# ទំនាក់ទំនងរវាងឆ្មបនិងស្ត្រីឬអតិថិជន

**មាត្រា ១១._**

ក្នុងករណីដែលស្ត្រី គ្រួសារ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកតំណាងស្របច្បាប់បដិសេធការព្យាបាលឬការថែទាំសុខភាព ឆ្មបត្រូវគោរពតាមការសម្រេចចិត្តរបស់អ្នកទាំងនោះ តែត្រូវពន្យល់អំពីផលវិបាកនានាដែលអាចកើតមានឡើង។

**មាត្រា ១២._**

ឆ្មបត្រូវជូនដំណឹងអំពីស្ថានភាពសុខភាពឬការវិវត្តនៃជំងឺដល់ស្ត្រី។ ការផ្តល់ដំណឹងដល់ប្តី ដៃគូ គ្រួសារ ឬតំណាងស្របច្បាប់ ត្រូវមានការយល់ព្រមពីសាមីខ្លួន។

**មាត្រា ១៣._**

ឆ្មបអាចបដិសេធមិនផ្តល់សេវាឆ្មបដល់ស្ត្រីណាម្នាក់ ដោយមានហេតុផលវិជ្ជាជីវៈឬហេតុផលផ្ទាល់ខ្លួនបាន លើកលែងតែក្នុងករណីសង្គ្រោះបន្ទាន់។ ប្រសិនបើសេវាឆ្មបត្រូវបានបដិសេធបែបនេះ ឆ្មបត្រូវបញ្ជូនស្ត្រីទៅកាន់សេវាជំនួសផ្សេងទៀត។

**មាត្រា ១៤.-**

ឆ្មបដែលត្រូវពិនិត្យអនីតិជនឬអសមត្ថជនពេញវ័យ ត្រូវជូនដំណឹងដល់ឪពុកម្ដាយ ឬអាណាព្យាបាល ឬអ្នកតំណាងស្របច្បាប់របស់ជននោះ ហើយឆ្មបត្រូវស្វែងរកការយល់ព្រមពីអ្នកទាំងនោះនៅមុនពេលចាប់ផ្ដើមផ្ដល់សេវា។

ក្នុងករណីបន្ទាន់ដែលអាចគ្រោះថ្នាក់ដល់ជីវិត ទោះបីជាមិនអាចធ្វើការទាក់ទងនឹងអ្នកទាំងនោះបានក៏ដោយ ក៏ឆ្មបត្រូវតែផ្ដល់សេវាជាចាំបាច់ដោយមានវត្តមាននិងការឯកភាពពីអ្នករួមការងារ។

ប្រសិនបើសាមីជនអាចបញ្ចេញមតិបាន ឆ្មបត្រូវពិចារណាដល់មតិនេះ បើអាចធ្វើទៅបាន។

**មាត្រា ១៥.-**

ឆ្មបត្រូវផ្ដល់ការការពារពិសេសចំពោះអនីតិជនឬអសមត្ថជនពេញវ័យ ប្រសិនបើអ្នកទាំងនោះមិនទទួលបានការថែទាំព្យាបាល ឬផលប្រយោជន៍ និងសិទ្ធិខាងសុខភាពបានត្រឹមត្រូវ។

ក្នុងករណីបែបនេះ ឆ្មបត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

**មាត្រា ១៦.-**

ឆ្មបឬគ្រឹះស្ថានឆ្មបត្រូវបង្ហាញតម្លៃសេវាទៅលើការពិនិត្យ ការពិគ្រោះយោបល់ ការថែទាំ ការព្យាបាល និងការផ្ដល់សេវាដទៃទៀត។/.

ឆ្មបអាចជូនដំណឹងដល់អ្នកជំងឺអំពីតម្លៃនិងការចំណាយចាំបាច់ផ្សេងៗមុនពេលផ្តល់សេវា លើកលែងតែក្នុងករណីសង្គ្រោះបន្ទាន់។

**មាត្រា ១៧.–**

ក្នុងករណីមានគ្រោះថ្នាក់ក្នុងទីសាធារណៈ ឆ្មបមិនត្រូវបោះបង់ស្ត្រីនិងទារកនោះទេ លើកលែងតែមានបទបញ្ជាណាមួយពីអាជ្ញាធរមានសមត្ថកិច្ចស្របតាមលក្ខខណ្ឌច្បាប់។

**មាត្រា ១៨.–**

ឆ្មបមិនត្រូវជ្រៀតជ្រែកក្នុងកិច្ចការគ្រួសារឬក្នុងជីវភាពផ្ទាល់ខ្លួនរបស់ស្ត្រីឡើយ បើពុំមានមូលហេតុវិជ្ជាជីវៈ។

# ជំពូកទី៤
## ទំនាក់ទំនងរវាងឆ្មបនិងសហភាតរៈ
## រវាងឆ្មបនិងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដទៃទៀត

**មាត្រា ១៩.-**

ឆ្មបត្រូវពង្រឹងទំនាក់ទំនងល្អជាមួយសហភាតរៈ និងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដទៃទៀត តាមរយៈការជំរុញ ការគាំទ្រគ្នាទៅវិញទៅមក ដើម្បីជាផលប្រយោជន៍ដល់ការថែទាំសុខភាពសាធារណៈ សុខុមាលភាពសហគមន៍និងកន្លែងធ្វើការ។

**មាត្រា ២០.-**

ឆ្មបត្រូវអនុវត្តករណីយកិច្ចរបស់ខ្លួន ដោយសហការជាមួយ ឬស្វែងរកដំបូន្មាន ឬសុំជំនួយពីឆ្មបដទៃឬពីគ្រូពេទ្យជំនាញតាមស្ថានភាពសមស្រប លើកលែងតែក្នុងករណីដែលការងារនោះផ្ទុយនឹងវិជ្ជាជីវៈឆ្មប។

**មាត្រា ២១._**

នៅពេលទទួលបានការប្រគល់ដើម្បីផ្តល់សេវាចំពោះស្ត្រី ដែលសហភាគរៈម្នាក់ទៀតបានផ្តល់សេវារួចហើយៈ

- ឆ្មបជំនួសត្រូវទទួលបានការយល់ព្រមជាមុនពីស្ត្រី
- ឆ្មបជំនួសត្រូវទាក់ទងជាមួយឆ្មបមុន ដើម្បីស្វែងរកយោបល់ឬដំបូន្មាន មុននឹងបន្តផ្តល់សេវាក្នុងការពិនិត្យថែទាំដល់ស្ត្រី
- នៅពេលបញ្ចប់ការជំនួស ឆ្មបជំនួសត្រូវបញ្ជូនសកម្មភាពពាក់ព័ន្ធនឹងការជំនួសទាំងអស់ និងប្រគល់ព័ត៌មានចាំបាច់ផ្សេងៗដល់ឆ្មបមុន ដើម្បីនិរន្តរភាពនៃការថែទាំព្យាបាល។

**មាត្រា ២២._**

ឆ្មបត្រូវគ្រប់គ្រងនិងទទួលខុសត្រូវលើនិស្សិតអន្តេវាសិកឆ្មបដែលកំពុងបំពេញការងារក្នុងកន្លែងធ្វើការរបស់ខ្លួន។

**មាត្រា ២៣._**

ឆ្មបមិនត្រូវបង្កើតក្រុមឬបណ្តាញក្នុងគោលបំណងដើម្បីរើសអើងសហភាគរៈឡើយ។

**មាត្រា ២៤._**

ឆ្មបមិនត្រូវធ្វើអ្វីដែលនាំឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ឆ្មបណាម្នាក់ឡើយ។

# ជំពូកទី៥
# ការប្រកបវិជ្ជាជីវៈឆ្មប

**មាត្រា ២៥.–**

ឆ្មបអាចបោះពុម្ពអត្តសញ្ញាណផ្ទាល់ខ្លួននិងព័ត៌មានមួយចំនួនដោយសុចរិតទៀងត្រង់ដូចខាងក្រោមនេះ៖

១- នាមត្រកូល នាមខ្លួន គុណវុឌ្ឍិ លេខចុះបញ្ជីក្នុងគណៈឆ្មបកម្ពុជា អាសយដ្ឋានប្រកបវិជ្ជាជីវៈ លេខទូរស័ព្ទ លេខទូរសារ អាសយដ្ឋានអ៊ីមែល គេហទំព័រ ថ្ងៃ និងពេលវេលាសម្រាប់ធ្វើការប្រឹក្សា។

២- នាមត្រកូលនិងនាមខ្លួនរបស់ឆ្មបទាំងអស់ក្នុងក្រុម ប្រសិនបើឆ្មបប្រកបមុខរបរជាក្រុម។

**មាត្រា ២៦.–**

ការបញ្ជាក់មួយចំនួនដែលឆ្មបឬគ្រឹះស្ថានឆ្មបត្រូវបានអនុញ្ញាតឱ្យសរសេរនៅលើស្លាកកន្លែងធ្វើការមាន៖

១- នាមត្រកូលនិងនាមខ្លួន លេខចុះបញ្ជីឆ្មបក្នុងគណៈឆ្មបកម្ពុជា អាសយដ្ឋានប្រកបវិជ្ជាជីវៈ លេខទូរស័ព្ទ លេខទូរសារ អាសយដ្ឋានអ៊ីមែល គេហទំព័រ។

២- នាមត្រកូលនិងនាមខ្លួន និងលេខចុះបញ្ជីឆ្មបក្នុងគណៈឆ្មបកម្ពុជានៃឆ្មបទាំងអស់ដែលប្រកបវិជ្ជាជីវៈនៅក្នុងគ្រឹះស្ថានឆ្មបនោះ។

៣- តារាងកំណត់តម្លៃសេវាពិនិត្យសុខភាព។

**មាត្រា ២៧.-**

ឆ្មបត្រូវបានអនុញ្ញាតឱ្យធ្វើការនៅស្ថាប័នឯកជន ក្នុងនាមជាឆ្មបឯកជន។

ប្រសិនបើឆ្មបធ្វើការនៅស្ថាប័នរដ្ឋផងនិងស្ថាប័នឯកជនផង ការងារឯកជនមិនត្រូវប៉ះពាល់ដល់ការងាររដ្ឋរបស់ខ្លួនឡើយ។

**មាត្រា ២៨.-**

ឆ្មបដែលផ្តល់សេវា ហើយកំពុងមានបញ្ហាជាមួយស្ត្រីទទួលសេវា មិនអាចជាសមាជិកគណៈកម្មការវិន័យឡើយ ។

ឆ្មបដែលធ្វើការនៅគ្រឹះស្ថានឆ្មបជាមួយគ្នា ឬជាញាតិលោហិតផ្ទាល់ ឬជាញាតិពន្ធក្នុងពថ្នាក់របស់ឆ្មប ឬមានទំនាក់ទំនងជាមួយនឹងឆ្មបដែលកំពុងជាប់ពាក់ព័ន្ធក្នុងសកម្មភាពដាក់វិន័យ មិនអាចជាសមាជិកគណៈកម្មការវិន័យឡើយ។

**មាត្រា ២៩.-**

ឆ្មបដែលជាសមាជិកគណៈកម្មការវិន័យត្រូវឯករាជ្យនៅក្នុងមុខងារ ត្រូវមានសមត្ថភាពក្នុងការបញ្ចេញទស្សនៈពាក់ព័ន្ធនឹងការវិភាគនិងការស្វែងរកដំណោះស្រាយចំពោះករណីដែលត្រូវត្រួតពិនិត្យ។

ឆ្មបមិនត្រូវលម្អៀងក្នុងការបង្ហាញហេតុផលឬធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធ ចំពោះករណីដែលខ្លួនត្រូវត្រួតពិនិត្យនោះទេ។

**មាត្រា ៣០.-**

ឆ្មបត្រួតពិនិត្យមិនត្រូវជ្រៀតជ្រែកឬកែប្រែការថែទាំព្យាបាលឡើយ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីនេះកំណត់ដោយច្បាប់។

**មាត្រា ៣១.-**

ឆ្មបត្រួតពិនិត្យត្រូវគោរពការសម្ងាត់វិជ្ជាជីវៈតាមបទប្បញ្ញត្តិដែលបានចែង។ របាយការណ៍ឬឯកសារដែលមានសម្គាល់អត្តសញ្ញាណរបស់ស្ត្រីទទួលសេវាឬរបស់ឆ្មបពិនិត្យថែទាំព្យាបាល មិនត្រូវបង្ហាញដល់ស្ថាប័នដែលមិនពាក់ព័ន្ធឬសាធារណជនឡើយ។

# ជំពូកទី៦
# បទប្បញ្ញត្តិផ្សេងៗ

**មាត្រា ៣២.-**

ឆ្មបទាំងអស់ នៅពេលសុំចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មប ត្រូវបញ្ជាក់នៅចំពោះមុខក្រុមប្រឹក្សាគណៈឆ្មបរាជធានី ខេត្តថាខ្លួនបានយល់ដឹងច្បាស់លាស់ពីអនុក្រឹត្យស្ដីពីក្រមសីលធម៌ឆ្មបនេះរួចហើយ និងសន្យាជាលាយលក្ខណ៍អក្សរថាគោរពតាមក្រមសីលធម៌នេះប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**មាត្រា ៣៣.-**

ឆ្មបដែលផ្ដល់សេចក្ដីបញ្ជាក់មិនត្រឹមត្រូវឬមិនពេញលេញដោយចេតនា ធ្វើឡើងជូនក្រុមប្រឹក្សាគណៈឆ្មប រាជធានី ខេត្ត អាចនាំឱ្យមានការចោទប្រកាន់ខាងវិន័យ។

**មាត្រា ៣៤.-**

ឆ្មបដែលឈប់ប្រកបមុខរបរឬកែប្រែលក្ខខណ្ឌនៃការប្រកបមុខរបរ ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាគណៈឆ្មប រាជធានី ខេត្ត។ ក្រុមប្រឹក្សាគណៈឆ្មបរាជធានី ខេត្ត ដែលទទួលដំណឹងអំពីការឈប់ឬការកែប្រែនេះ ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាគណៈឆ្មបជាតិ។

**មាត្រា ៣៥.-**

សេចក្តីសម្រេចទាំងឡាយរបស់គណៈឆ្មបគ្រប់ជាន់ថ្នាក់ក្នុងការអនុវត្តតាមអនុក្រឹត្យនេះ ត្រូវតែមានមូលហេតុច្បាស់លាស់។

**មាត្រា ៣៦.-**

ក្នុងករណីដែលមិនយល់ស្របនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈឆ្មបរាជធានី ខេត្ត ស្ត្រីទទួលសេវាឬឆ្មបដែលផ្តល់សេវាមានរយៈពេល២ខែ ដើម្បីសុំឱ្យក្រុមប្រឹក្សាគណៈឆ្មបជាតិពិនិត្យសេចក្តីសម្រេចនោះឡើងវិញ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា ៣៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល

# សូមអរគុណ